រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និង ក្រសួងពាក់ព័ន្ធ ព្រមទាំង ឯកឧត្តម អស់លោក សាមីជន ដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ ។

**មាត្រា ៥ :** អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានិងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឬទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ ១៩ អនក្រ.បក
## ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេស
## ស្តីពីកិច្ចការព្រំដែន

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហា ក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋា ភិបាល ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត « អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន » ដែលជំនួសអោយព្រះរាជក្រឹត្យ លេខ នស/រកត/០២៩៥/១៩ ចុះថ្ងៃទី ២៥ កុម្ភៈ ឆ្នាំ ១៩៩៥ ។
- យោងតាមសំណូមពរការងារចាំបាច់ ។

**សំរេច**

**មាត្រា ១** : បង្កើតគណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែន ដែលមានសមាសភាពដូចតទៅ :

**១–សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ** : ប្រធាន

២–ឯកឧត្តម ឧត្តមសេនីយ៍ត្រី **ចំរើន ជាតិ** មេបញ្ជាការកងការពារព្រំដែន នៃក្រសួងការពារជាតិ អនុប្រធាន

៣–ឧត្តមសេនីយ៍ត្រី **រស់គីមសាន** នាយក នាយកដ្ឋានភូមិសាស្ត្រនៃក្រសួងការពារជាតិ សមាជិក

៤–ឯកឧត្តម **ហ៊ុន ណេង** អភិបាលខេត្ត កំពង់ចាម សមាជិក

៥–ឯកឧត្តម **ឡូយ សុផាត** អភិបាលខេត្ត ស្វាយរៀង សមាជិក

៦–ឯកឧត្តម **ទេព ននៃ្ទរី** អភិបាលខេត្ត ព្រៃវែង សមាជិក

៧–ឯកឧត្តម **ស៊ូ តីរ៉ន្ទ** អភិបាលខេត្ត តាកែវ សមាជិក

៨–ឯកឧត្តម **រ៉ុង ផ្លាមកេសន** អភិបាលខេត្ត កោះកុង សមាជិក

៩–ឯកឧត្តម **អ៊ុង សាមី** អភិបាលខេត្ត បាត់ដំបង សមាជិក

១០–ឯកឧត្តម **ដួង ខេម** អភិបាលខេត្ត បន្ទាយមានជ័យ សមាជិក

១១–ឯកឧត្តម **ទន់ ចាយ** អភិបាលខេត្ត សៀមរាប សមាជិក

១២–ឯកឧត្តម **លី ស៊ូ** អភិបាលខេត្ត ស្ទឹងត្រែង សមាជិក

| | | | |
|---|---|---|---|
| ១៣-ឯកឧត្តម | **កែប ជុតិមា** | អភិបាលខេត្ត រតនគិរី | សមាជិក |
| ១៤-ឯកឧត្តម | **នូ គៀង** | អភិបាលខេត្ត ក្រចេះ | សមាជិក |
| ១៥-ឯកឧត្តម | **ជុំ ឈឿង** | អភិបាលខេត្ត មណ្ឌលគិរី | សមាជិក |
| ១៦-ឯកឧត្តម | **គុណ គីមតេង** | អភិបាលខេត្ត កំពត | សមាជិក |
| ១៧-ឯកឧត្តម | **មាន សារិន** | អភិបាលខេត្ត ព្រះវិហារ | សមាជិក |
| ១៨-ឯកឧត្តម | **ចក់ សារិក** | អភិបាលខេត្ត កណ្ដាល | សមាជិក |
| ១៩-ឯកឧត្តម | **រស់ ស្រេង** | អភិបាលខេត្ត ពោធិសាត់ | សមាជិក |
| ២០-លោក | **អ៊ាត លីហេង** | អនុប្រធាននាយកដ្ឋានអាស៊ីនិង អូស្ត្រាលី នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២១-លោក | **ហួន សាវ៉ាង** | អនុប្រធាននាយកដ្ឋានភូមិសាស្ត្រ នៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២២-លោក | **លឹម វ៉ាន់** | ប្រធានស្ដីទីនាយកដ្ឋានសុរិយោដី នៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២៣-លោក | **ម៉ែន អ៊ាន** | ប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក ក្រសួងមហាផ្ទៃ | សមាជិក |
| ២៤-លោក | **ជេត ខេមរា** | មន្ត្រីនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ និងរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ | សមាជិក |
| ២៥-លោក | **ភូលិន្ទ មុនី** | មន្ត្រីនាយកដ្ឋានអាស៊ីទទួលបន្ទុកវៀតណាម នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២៦-លោក | **ឌី សុផាន** | អនុប្រធានទី ១ នាយកដ្ឋានកិច្ចការនយោបាយនៃក្រសួងមហាផ្ទៃ លេខាធិការ | |

**មាត្រា ២ :** គណៈកម្មាធិការបច្ចេកទេសស្ដីពីកិច្ចការព្រំដែននេះ មានខ្សែបណ្ដាញជាភ្នាក់ងារកិច្ចការព្រំដែន រហូតដល់ខេត្ត និង ស្រុក ។

**មាត្រា ៣ :** គណៈកម្មាធិការបច្ចេកទេសស្ដីពីកិច្ចការព្រំដែន មានភារកិច្ចត្រួតពិនិត្យការពារបន្ទាត់ព្រំដែនក្នុងរយៈរង់ចាំការដោះស្រាយ ធ្វើអន្តរាគមន៍ដោះស្រាយ ចំពោះបាតុភាព ឬទំនាស់ព្រំដែនជាមួយខេត្តជាប់ព្រំដែនរបស់ប្រទេសជិតខាង និងចុះធ្វើការវាស់វែងបោះគោលបន្ទាត់ព្រំដែន តាមស្មារតីនៃលទ្ធផលដែលទទួលបានពីអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។ ចូលរួមជាមួយគណៈកម្មាធិការនីតិកម្ម ក្នុងការចរចាដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងតាមការចាំបាច់ ។

**មាត្រា ៤ :** គណៈកម្មាធិការបច្ចេកទេសស្ដីពីកិច្ចការព្រំដែន មានលេខាធិការដ្ឋានជាជំនួយការរដ្ឋបាល និងសំរបសំរួលការងារដែលមានទីស្នាក់ការនៅក្រសួងមហាផ្ទៃ ។ គណៈកម្មាធិការបច្ចេកទេសស្ដីពីកិច្ចការព្រំដែននេះ ជាផ្នែកមួយរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនដែលមានទីតាំងនៅនាយកដ្ឋានភូមិសាស្ត្រនៃទីស្ដីការគណៈរដ្ឋមន្ត្រី ។ លេខានៃលេខាធិការដ្ឋាននៃគណៈកម្មាធិការបច្ចេកទេសស្ដីពីកិច្ចការព្រំដែននេះត្រូវជាសមាជិកនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍របស់អាជ្ញាធរជាតិ ទទួលបន្ទុកកិច្ចការ ព្រំដែន ។ ក្នុងករណីចាំបាច់គណៈកម្មាធិការបច្ចេកទេសនេះអាចបង្កើតឬរៀបចំអនុគណៈកម្មការផ្សេង ៗ ដើម្បីសំរបសំរួលឬបំពេញភារកិច្ចរបស់គណៈកម្មាធិការបច្ចេកទេសនេះអោយមានប្រសិទ្ធភាព ។

**មាត្រា ៥ :** សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ឯកឧត្តមអភិបាលខេត្តជាប់ព្រំដែន និងសាមីជនដែលមានឈ្មោះចែងក្នុងមាត្រា ១ ព្រមទាំងក្រសួង និង ស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវទទួល

អនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ ២០ អនក្រ.បក
## ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់
## ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង ទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស.រកត. ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស រកត.១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- តាមតម្រូវការនៃការរៀបចំគ្រប់គ្រង និង ការប្រព្រឹត្តិទៅរបស់ក្រសួង និង